

# នីន ចង់ស្លៀកពាក់

Bounhome Khensonema

Aphisith Souphavongtay

Let's Read
The Asia Foundation



ថ្ងៃនេះជាថ្ងៃចូលរៀនដំបូងរបស់ នីន។ ប៉ុន្តែនាងមិនអាច
ស្លៀកពាក់ឯកសណ្ឋានដោយខ្លួនឯងបានទេ។



នាងរត់ទៅរកម៉ាក់ឱ្យជួយ។



” ម៉ាក់ៗ ជួយស្លៀកពាក់ឱ្យកូនបន្តិចបានទេ? ” នីន សួរ។
ម៉ាក់ឆ្លើយថា ” ចាស ចាំម៉ាក់ជួយពេលម៉ាក់ធ្វើម្ហូបរួច ” ។



នីន រត់ទៅក្រៅដើម្បីរកអ្នកផ្សេងឱ្យជួយ។



នីនសួរថា "ប៉ាៗ ជួយស្លៀកពាក់ឱ្យកូនបន្តិចបានទេ?"
ប៉ាឆ្លើយថា "ចាំប៉ាជួយ ពេលប៉ាឱ្យចំណីទារួច"



”តាៗ ជួយស្លៀកពាក់ឱ្យចៅបន្តិចបានទេ?” នីនសួរ។ លោកតាឆ្លើយថា ”តាកំពុងជាប់ដឹកគោទៅវាល ពេលតាមកវិញ ចាំតាជួយ”។



"យាយៗ ជួយស្មៀកពាក់ឱ្យចៅបន្តិចបានទេ?" នីន សួរ។ លោកយាយឆ្លើយ "ចាំយាយជួយ ពេលយាយបោសទីធ្លារួច"។



”បងឡា! ជួយស្លៀកពាក់ឱ្យអូនបន្តិចបានទេ?” នីន សួរ។ បងឡាឆ្លើយថា ”ចាំបងជួយឯងពេលបងដងទឹកពីអណ្តូងរួចសិន”។



នីន គិតដោយតូចចិត្តថា គ្មានអ្នកអាចជួយនាងបានសោះ។



គ្រប់គ្នាសុទ្ធតែរវល់!



នីន ក៏សម្រេចចិត្តស្លៀកពាក់ដោយខ្លួនឯង។ ដំបូងនាងពាក់វា
បញ្ច្រាស។ បន្ទាប់មក នាងពាក់វាពីក្រោយទៅមុខ។



បន្ទាប់មកទៀត នីន សាកពាក់ស្បែកជើង។



នីន មើលទៅក្នុងកញ្ចក់។ ចប់បាត់ហើយ! ឯកសណ្ឋាននាងស្លៀកពាក់ខុសទាំងអស់!



គ្រួសាររបស់នាងឃើញហើយក៏សើចតិចៗ។
លោកយាយនិយាយថា "ចាំយាយជួយ"។
ឪពុក និងបងឡា ក៏និយាយថា "ពួកយើងក៏ជួយ"។



ទីបំផុត នីន អាចទៅរៀនបានហើយ។ ថ្ងៃដំបូងសូមសំណាងល្អ នីន!

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**

*Nin Wants to Get Dressed*, Author: Bounhome Khensonema. Illustrator: Aphisith Souphavongtay. Published by Room to Read, © Room to Read. Released under CC-BY-4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC-BY-4.0.
Contributing translators: Somey Chheang, Nita Chea, and Chou Chinith